ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

លេខ ០៣១ សនក./ប្រក

# ប្រកាសអន្តរក្រសួង

## ស្តីពី

## ការតម្លើងកម្រិត និងការបង្កើតអង្គភាពសុខាភិបាល

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ        រដ្ឋមន្ត្រីក្រសួងសុខាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ ១០៩អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ១៩៣អនក្រ.បក ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីការប្រគល់មុខងារគ្រប់គ្រង និងផ្តល់សេវាសុខាភិបាលទៅឲ្យរដ្ឋបាលរាជធានី ខេត្ត
- បានឃើញប្រកាសអន្តរក្រសួងលេខ១៥២ សនក ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២០ របស់ក្រសួងសុខាភិបាល និងក្រសួងមហាផ្ទៃ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មន្ទីរសុខាភិបាលនៃរដ្ឋបាលរាជធានី ខេត្ត
- បានឃើញប្រកាសលេខ១៦១ ស.នប ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៨ របស់ក្រសួងសុខាភិបាល ស្តីពីការបង្កើតមន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាព ចំណុះមន្ទីរសុខាភិបាលរាជធានីភ្នំពេញ



ទីស្តីការក្រសួងសុខាភិបាល ជីឡូតិ៍លេខ ៨០ វិថីសម្តេច ប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩

- យោងលិខិតលេខ៤៤៨៦ សហវ.អថ ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២២ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការឯកភាពក្នុងការបង្កើតអង្គភាពសុខាភិបាលសម្រាប់ឆ្នាំ២០២២ ចំនួន២២កន្លែង
- យោងលិខិតលេខ៩៩៩/២២ មស.នក ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២២ របស់ក្រសួងមុខងារសាធារណៈ ស្តីពីការឯកភាព ក្នុងការតម្លើងកម្រិត និងបង្កើតអង្គភាពសុខាភិបាលថ្មីចំនួន ២២កន្លែង
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសុខាភិបាល និងក្រសួងមហាផ្ទៃ

**សម្រេច**

**ប្រការ១.**_

ត្រូវបានតម្លើងមន្ទីរពេទ្យបង្អែកខេត្តឧត្តរមានជ័យ ដែលបច្ចុប្បន្នកំពុងផ្តល់សេវាសំណុំសកម្មភាពបង្គ្រប់កម្រិត២ (CPA2) ទៅជាមន្ទីរពេទ្យបង្អែកខេត្តឧត្តរមានជ័យ ផ្តល់សេវាសំណុំសកម្មភាពបង្គ្រប់កម្រិត៣ (CPA3) ស្ថិតនៅភូមិឈូក ឃុំសំរោង ក្រុងសំរោង ខេត្តឧត្តរមានជ័យ ក្រោមការគ្រប់គ្រងរបស់ មន្ទីរសុខាភិបាលនៃរដ្ឋបាលខេត្តឧត្តរមានជ័យ។

**ប្រការ២.**_

ត្រូវបានតម្លើងមន្ទីរពេទ្យបង្អែកអង្គរជុំ ដែលបច្ចុប្បន្នកំពុងផ្តល់សេវាសំណុំសកម្មភាពបង្គ្រប់កម្រិត១ (CPA1) ទៅជាមន្ទីរពេទ្យបង្អែកអង្គរជុំ ផ្តល់សេវាសំណុំសកម្មភាពបង្គ្រប់កម្រិត២ (CPA2) ស្ថិតនៅភូមិក្បាលចាម ឃុំចារឈូក ស្រុកអង្គរជុំ ខេត្តសៀមរាប ក្រោមការគ្រប់គ្រងរបស់ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិអង្គរជុំ នៃមន្ទីរសុខាភិបាលនៃរដ្ឋបាលខេត្តសៀមរាប។

**ប្រការ៣.**_

ត្រូវបានបង្កើតមន្ទីរពេទ្យបង្អែកថ្មីចំនួន០១កន្លែង ជាមន្ទីរពេទ្យបង្អែក ផ្តល់សេវាសំណុំសកម្មភាពបង្គ្រប់កម្រិត១ (CPA1) គឺមន្ទីរពេទ្យបង្អែកកែវសីមា ស្ថិតនៅភូមិអូរអាម ឃុំស្រែខ្ទុម ស្រុកកែវសីមា ខេត្តមណ្ឌលគិរី ក្រោមការគ្រប់គ្រងរបស់ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិសែនមនោរម្យ នៃមន្ទីរសុខាភិបាលនៃរដ្ឋបាលខេត្តមណ្ឌលគិរី។

**ប្រការ៤.**_

ត្រូវបានតម្លើងប៉ុស្តិ៍សុខភាព ទៅជាមណ្ឌលសុខភាព ចំនួន០៥កន្លែង ស្ថិតក្រោមឱវាទមន្ទីរសុខាភិបាលនៃរដ្ឋបាលខេត្ត ចំនួន ៣ ដូចខាងក្រោម៖

**ក.រដ្ឋបាលខេត្តមណ្ឌលគិរី**

១-តម្លើងប៉ុស្តិ៍សុខភាពអូរក្ល ទៅជាមណ្ឌលសុខភាពអូរក្ល ស្ថិតនៅភូមិអូរក្លព្រៃមាស ឃុំចុងផ្លាស់ ស្រុកកែវសីមា ខេត្តមណ្ឌលគិរី ក្រោមការគ្រប់គ្រងរបស់ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិសែនមនោរម្យ

២-តម្លើងប៉ុស្តិ៍សុខភាពស្រែឈូក ទៅជាមណ្ឌលសុខភាពស្រែឈូក ស្ថិតនៅភូមិចក់ចារ ឃុំស្រែឈូក ស្រុកកែវសីមា ខេត្តមណ្ឌលគិរី ក្រោមការគ្រប់គ្រងរបស់ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិសែនមនោរម្យ

៣-តម្លើងប៉ុស្តិ៍សុខភាពពាមជីមៀត ទៅជាមណ្ឌលសុខភាពពាមជីមៀត ស្ថិតនៅភូមិណងបួ ឃុំណងឃិលីក ស្រុកកោះញែក ខេត្តមណ្ឌលគិរី ក្រោមការគ្រប់គ្រងរបស់ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិសែនមនោរម្យ។

**ខ.រដ្ឋបាលខេត្តពោធិ៍សាត់**

១-តម្លើងប៉ុស្តិ៍សុខភាពអូរសោម ទៅជាមណ្ឌលសុខភាពអូរសោម ស្ថិតនៅភូមិអូរសោម ឃុំអូរសោម ស្រុកវាលវែង ខេត្តពោធិ៍សាត់ ក្រោមការគ្រប់គ្រងរបស់ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិភ្នំក្រវាញ។

**គ.រដ្ឋបាលខេត្តសៀមរាប**

១-តម្លើងប៉ុស្តិ៍សុខភាពកំពង់ភ្លុក ទៅជាមណ្ឌលសុខភាពសៀងណាំកំពង់ភ្លុក ស្ថិតនៅភូមិត្នោតកំបុត ឃុំកំពង់ភ្លុក ស្រុកប្រាសាទបាគង ខេត្តសៀមរាប ក្រោមការគ្រប់គ្រងរបស់ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិសៀមរាប។

**ប្រការ៥._**

ត្រូវបានបង្កើតមណ្ឌលសុខភាពថ្មី ចំនួន ១៣កន្លែង ស្ថិតក្រោមឱវាទមន្ទីរសុខាភិបាលនៃរដ្ឋបាលខេត្តចំនួន ៧ ដូចខាងក្រោម៖

**ក.រដ្ឋបាលខេត្តឧត្តរមានជ័យ**

១-មណ្ឌលសុខភាពដីក្រហម ស្ថិតនៅភូមិដីក្រហម ឃុំត្រពាំងប្រាសាទ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ក្រោមការគ្រប់គ្រងរបស់ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិអន្លង់វែង។

**ខ.រដ្ឋបាលខេត្តកំពង់ស្ពឺ**

១-មណ្ឌលសុខភាពតាំងសំរោង ស្ថិតនៅភូមិជ្រៃសែនជ័យ ឃុំតាំងសំរោង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ក្រោមការគ្រប់គ្រងរបស់ការិយាល័យសុខាភិបាល ស្រុកប្រតិបត្តិភ្នំស្រួច

២-មណ្ឌលសុខភាពត្រាចទង ស្ថិតនៅភូមិត្រពាំងលើក ឃុំត្រាចទង ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ ក្រោមការគ្រប់គ្រងរបស់ការិយាល័យសុខាភិបាល ស្រុកប្រតិបត្តិឧដុង្គ។

**គ.រដ្ឋបាលខេត្តពោធិ៍សាត់**

១-មណ្ឌលសុខភាពអូរសណ្តាន់ ស្ថិតនៅភូមិអូរអាចម៍កុក ឃុំអូរសណ្តាន់ ស្រុកក្រគរ ខេត្តពោធិ៍សាត់ ក្រោមការគ្រប់គ្រងរបស់ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិក្រគរ

២-មណ្ឌលសុខភាពអន្លង់ត្នោត ស្ថិតនៅភូមិជ្រលង ឃុំអន្លង់ត្នោត ស្រុកក្រគរ ខេត្តពោធិ៍សាត់ ក្រោមការគ្រប់គ្រងរបស់ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិក្រគរ

៣-មណ្ឌលសុខភាពឧទ្យានសំកុសសែនជ័យ ស្ថិតនៅភូមិក្រពើពីរក្រោម ឃុំក្រពើពីរ ស្រុកវាលវែង ខេត្តពោធិ៍សាត់ ក្រោមការគ្រប់គ្រងរបស់ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិភ្នំក្រវាញ

៤-មណ្ឌលសុខភាពរវៀង ស្ថិតនៅភូមិរវៀង ឃុំសំរោង ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ ក្រោមការគ្រប់គ្រងរបស់ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិភ្នំក្រវាញ

៥-មណ្ឌលសុខភាពសន្ទ្រែ ស្ថិតនៅភូមិសន្ទ្រែ ឃុំសន្ទ្រែ ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ ក្រោមការគ្រប់គ្រងរបស់ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិភ្នំក្រវាញ

៦-មណ្ឌលសុខភាពរកាត ស្ថិតនៅភូមិវាលវង់ ឃុំរកាត ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ ក្រោមការគ្រប់គ្រងរបស់ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិភ្នំក្រវាញ។

**ឃ.រដ្ឋបាលខេត្តស្វាយរៀង**

១-មណ្ឌលសុខភាពគគីរសោម ស្ថិតនៅភូមិសង្គម ឃុំគគីរសោម ស្រុកស្វាយទាប ខេត្តស្វាយរៀង ក្រោមការគ្រប់គ្រងរបស់ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិស្វាយទាប។

**ង.រដ្ឋបាលខេត្តព្រះសីហនុ**

១-មណ្ឌលសុខភាពទំនប់រលក ស្ថិតនៅភូមិ២ ឃុំទំនប់រលក ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ ក្រោមការគ្រប់គ្រងរបស់ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិព្រះសីហនុ។

**ច.រដ្ឋបាលខេត្តតាកែវ**

១-មណ្ឌលសុខភាពពារាម ស្ថិតនៅភូមិក្រាំងក្រចាង ឃុំពារាម ស្រុកបាទី ខេត្តតាកែវ ក្រោមការគ្រប់គ្រងរបស់ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិបាទី។

**ឆ.រដ្ឋបាលខេត្តកំពង់ធំ**

១-មណ្ឌលសុខភាពផាត់សណ្ដាយ ស្ថិតនៅភូមិផាត់សណ្ដាយ ឃុំផាត់សណ្ដាយ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ក្រោមការគ្រប់គ្រងរបស់ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិកំពង់ធំ។

**ប្រការ៦.**_

ត្រូវបានបង្កើតប៉ុស្តិ៍សុខភាពថ្មី ចំនួន ១ កន្លែងគឺ ប៉ុស្តិ៍សុខភាពអាយុយឺនយូរ អូរបាក់រទេះ ស្ថិតក្រោមមណ្ឌលសុខភាពថ្មី នៅភូមិស្ទឹងច្រាល ឃុំអូរបាក់រទេះ ស្រុកកំពង់សីលា ខេត្តព្រះសីហនុ ក្រោមការគ្រប់គ្រងរបស់ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិព្រះសីហនុ នៃមន្ទីរសុខាភិបាលនៃរដ្ឋបាលខេត្តព្រះសីហនុ។

**ប្រការ៧.**_

ត្រូវបានផ្ទេរការគ្រប់គ្រងមណ្ឌលសុខភាពប្រទះឡាង ពីការិយាល័យសុខាភិបាលស្រុកប្រតិបត្តិដង្កោ ឲ្យស្ថិតក្រោមការគ្រប់គ្រងរបស់ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិពោធិ៍សែនជ័យ នៃមន្ទីរសុខាភិបាលនៃរដ្ឋបាលរាជធានីភ្នំពេញ។

**ប្រការ៨.**_

អគ្គលេខាធិការ នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធ នៃក្រសួងមហាផ្ទៃ និងក្រសួងសុខាភិបាល ព្រមទាំងក្រុមប្រឹក្សា និងគណៈអភិបាលរាជធានី ខេត្ត និងប្រធានមន្ទីរសុខាភិបាល នៃរដ្ឋបាលរាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ អង្គារ ១៣កើត ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២២

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** | **រដ្ឋមន្ត្រីក្រសួងសុខាភិបាល**

**សម្ដេចក្រឡាហោម ស ខេង** | **ម៉ម ប៊ុនហេង**

**កន្លែងទទួល**:
-ទីស្ដីការគណៈរដ្ឋមន្ត្រី
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងមុខងារសាធារណៈ
-ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្ដេច ឯកឧត្ដម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
-លេខាធិការដ្ឋាន គ.ជ.អ.ប
-ដូចប្រការ៨
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ